**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតឡើងនូវគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលសរសេរជាអក្សរកាត់ថា **គ.ព.ស.គ.ញ.** ដើម្បីធ្វើជាសេនាធិការជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការដឹកនាំលើការផ្តល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀនទៅក្នុងសង្គមវិញ។

## ជំពូកទី២
## សមាសភាពរបស់ គ.ព.ស.គ.ញ.

**មាត្រា២ .-**

**គ.ព.ស.គ.ញ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១ រូប | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ជ.ប.គ.ញ.** | | សមាជិក |
| - អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | សមាជិក |
| - អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| - មេបញ្ជាការរងនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១ រូប | សមាជិក |

- អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ១ រូប សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក

សមាសភាពជាក់ស្ដែងនៃ **គ.ព.ស.គ.ញ.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ព.ស.គ.ញ.

**មាត្រា៣ .-**

**គ.ព.ស.គ.ញ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការប្រតិបត្តិ នីតិវិធី និងឯកសារចាំបាច់ផ្សេងៗទៀតពាក់ព័ន្ធការងារផ្ដល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀន ទាំងនៅក្នុងមណ្ឌលថ្នាក់ជាតិ មណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋនិងឯកជន ពន្ធនាគារ និងនៅក្នុងសេវាព្យាបាលដោយផ្អែកលើសហគមន៍ទៅក្នុងសង្គមវិញ
- ដឹកនាំសម្របសម្រួលគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ដើម្បីជានាឲ្យដំណើរការនៃការផ្ដល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀន ក្នុងមណ្ឌលព្យាបាលគ្រប់កម្រិតរបស់រដ្ឋនិងឯកជន ពិសេសការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ បានប្រព្រឹត្តទៅមានភាពរលូននិងប្រសិទ្ធភាព
- ដឹកនាំសម្របសម្រួលនិងរៀបចំប្រព័ន្ធព័ត៌មាន ប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន និងទិន្នន័យផ្សេងៗទៀត ពាក់ព័ន្ធនឹងការងារផ្ដល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀន
- ពង្រឹងនិងបង្កើតយន្តការ ដើម្បីធានាប្រសិទ្ធភាពនិងនិរន្តរភាពនៃការងារផ្ដល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងក្នុងសហគមន៍ស្របតាមឯកសារក្របខ័ណ្ឌទស្សនាទានរបស់ក្រសួងសុខាភិបាលស្ដីពីការបង្ការ ថែទាំ ព្យាបាលបន្ត និងស្ដារនីតិសម្បទាចិត្ត សង្គម ចំពោះអ្នកប្រើគ្រឿងញៀននិងអ្នកចាក់គ្រឿងញៀន
- ពង្រឹងប្រសិទ្ធភាពនៃការងារសម្របសម្រួលអន្តរវិស័យ និងចលនាឲ្យមានការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងកៀរគរធនធានសម្រាប់ផ្ដល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ ធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀនប្រកបដោយស្ដង់ដារនីតិ...

- តាមដាននិងវាយតម្លៃជាទៀងទាត់ ក្នុងការងារផ្តល់សេវាព្យាបាល បង្ការ ថែទាំបន្ត និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនដែលបានរងគ្រោះដោយសារគ្រឿងញៀន
- លើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ព.ស.គ.ញ.**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួនជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់គ.ព.ស.គ.ញ.

**មាត្រា៤ .-**

**គ.ព.ស.គ.ញ.** ត្រូវធ្វើការប្រជុំរៀងរាល់៣(បី)ខែម្តងនិងអាចកោះប្រជុំតាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៥ .-**

**គ.ព.ស.គ.ញ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះយោបល់សិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខណ្ឌការងាររបស់ខ្លួនបាន។

**មាត្រា៦ .-**

បែបបទនិងនីតិវិធីការងាររបស់ **គ.ព.ស.គ.ញ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់**គ.ព.ស.គ.ញ.**។

**មាត្រា៧ .-**

**គ.ព.ស.គ.ញ.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងនៅក្រសួងសុខាភិបាល។

លេខាធិការដ្ឋាន **គ.ព.ស.គ.ញ.** ត្រូវដឹកនាំដោយប្រធានលេខាធិការដ្ឋានមួយរូប និងមានអនុប្រធានលេខាធិការដ្ឋានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ព.ស.គ.ញ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ព.ស.គ.ញ.**។

**មាត្រា៨ .-**

**គ.ព.ស.គ.ញ.** មានសិទ្ធិប្រើត្រារបស់ក្រសួងសុខាភិបាល ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## ធនធាននិងមូលនិធិរបស់ គ.ព.ស.គ.ញ.

**មាត្រា៩ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **គ.ព.ស.គ.ញ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសុខាភិបាល។ ចំណាយសម្រាប់ដំណើរការរបស់ **គ.ព.ស.គ.ញ.** ពុំរួមបញ្ចូលប្រាក់បៀវត្សរ៍និងប្រាក់លាភការរបស់សមាជិកដែលជាសមាសភាពរបស់ **គ.ព.ស.គ.ញ.** នោះទេ។

**គ.ព.ស.គ.ញ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវ[illegible]

មកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។ **គ.ព.ស.គ.ញ.** ត្រូវធ្វើរបាយការណ៍ចំណូលចំណាយ មូលនិធិរបស់ **គ.ព.ស.គ.ញ.** ដែលទទួលបានពីថវិកាជាតិនិងប្រភពផ្សេងៗក្រៅពីថវិកាជាតិរៀងរាល់ ៦(ប្រាំមួយ)ខែម្តង ជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**កែ គឹមយ៉ាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ